# អ្នកស្រែខ្មែរ និង ពាណិជ្ជករចិន

ដោយសារបានកំរៃពីការលក់ដូរផលិតផលនៅទីផ្សារ អ្នកស្រែចាយលុយទិញទំនិញ និង របស់របរសំខាន់ៗតាមផ្ទះចិន មុននឹងត្រឡប់ទៅភូមិរៀងៗខ្លួនវិញ ។ ភូមិស្នាយពលមានភូមិតូចៗជាច្រើន នៅជុំវិញ ។ ភូមិនេះជាមជ្ឈមណ្ឌលពាណិជ្ជកម្មប្រចាំស្រុក ។ អ្នកស្រែមកពីភូមិទាំងនោះរៀងរាល់ថ្ងៃ ទាំងព្រឹក ទាំងល្ងាច ដើម្បីទិញអីវ៉ាន់យកទៅទុកប្រើប្រាស់ ។ អ្នកស្រែ និង ពាណិជ្ជករចិនទាំងនោះមានទំនាក់ទំនងគ្នាល្អណាស់ ។ គេអាចមកទិញអីវ៉ាន់ពេលណាក៏បាន យប់ក៏បាន ថ្ងៃក៏បាន ។ សំខាន់បំផុត បើមិនទាន់មានលុយ អ្នកស្រែក៏អាចទិញទំនិញ ឬអីវ៉ែអីវ៉ាន់ពីពាណិជ្ជករចិនបានដែរ ដោយសារគេអាចជឿបណ្តាក់គ្នាបាន ។ ពេលយប់ គេអាចមកគោះទ្វារផ្ទះចិន ដើម្បីទិញរបស់របរ ដែលគេត្រូវការជាបន្ទាន់ដូចជា៖ ថ្នាំសង្កូវ ប្រេងកាត ឬ សំលៀកបំពាក់ ឬ ភេសជ្ជៈចាំបាច់ជាដើម ។ ពាណិជ្ជករចិនមិនប្រញាប់ប្រញាល់ទារប្រាក់ជំពាក់ភ្លាមទេ គេគ្រាន់តែកត់ត្រាទុករួច គេរង់ចាំរដូវច្រូតកាត់ រដូវប្រមូលផលក្នុងខែចុងឆ្នាំ ទើបគេទូទាត់គ្នាម្តង ។ ក៏ប៉ុន្តែ អ្នកស្រែត្រូវបង់ការប្រាក់ខ្ពស់ ដែលជួនកាលការប្រាក់នោះ កាន់តែកើនច្រើនឡើងៗបន្ថែមលើប្រាក់កម្ចីដើម ។ អ្នកស្រែច្រើនធ្វើការទូទាត់ប្រាក់ជំពាក់ទាំងដើមទាំងការនោះដែលគេគិតជារង្វាល់ស្រូវតាមចំនួនតៅ ឬ ថាំង[6] ។ ក្រោយដែលទូទាត់បំណុលរួចហើយ អ្នកស្រែច្រើនទុកផលស្រូវសេសសល់នៅក្នុងជង្រុក សំរាប់ទទួលទាន ឬ ទុកលក់បណ្តើរៗក្នុងរដូវខាងមុខ ។ ដូច្នេះ ប្រសិនបើផលស្រូវបានច្រើន អ្នកស្រែអាចនៅសល់ស្រូវច្រើនដែលគេអាចដូរយកខោអាវសំលៀកបំពាក់ ឬ របស់របរប្រើប្រាស់បានច្រើន ។ អ្នកស្រែសម័យនោះភាគច្រើន រកបានគ្រាន់តែសម្រាប់

---

[6] តៅ និង ថាំងជារង្វាស់រង្វាល់ខ្មែរពីបូរាណ ។ ជាធម្មតា ក្នុងមួយថាំង មានពីរតៅ ។

សងបំណុលចិនប៉ុណ្ណោះ ។

អ្នកស្រែមួយចំនួនមានដីធ្វើស្រែផង និង មានដីសំរាប់សង់ផ្ទះផង ។ ក៏ប៉ុន្តែ អ្នកស្រែខ្លះ មិនបានទទួលផលគ្រប់គ្រាន់ ពុំអាចឲ្យមានលទ្ធភាពសងបំណុលចាស់បាន ។ ដូច្នេះ ពីមួយឆ្នាំទៅមួយឆ្នាំ អ្នកស្រែនោះជំពាក់បំណុលចិនកាន់តែច្រើន ដែលនៅទីបញ្ចប់ត្រូវថៅកែចិនរឹបអូសយកដីធ្លីអស់ផង ។ ក្នុងករណីនេះ ពួកគាត់ត្រូវធ្វើស្រែប្រវាស់គ្នាជាមួយចិន ។ ពួកចិនជាអ្នកកំណត់តម្លៃទំនិញនៅទីផ្សារ ។ តម្លៃទីផ្សារឡើងចុះស្រេចទៅលើសហគមន៍ចិន ដែលមានខ្សែរយៈតាមបណ្តាញរបស់គេនៅទូទាំងប្រទេស ។ ថៅកែចិនជាអ្នកផ្តល់ទំនិញទៅដល់អ្នកភូមិ ទៅតាមប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ តាមការជាក់ស្តែង អ្នកស្រែជាអ្នកទិញ ជាអ្នកត្រូវការជានិច្ច រីឯថៅកែចិនជាអ្នកផ្តល់ ជាអ្នកផ្គត់ផ្គង់ ។ សេចក្តីត្រូវការរបស់អ្នកស្រែខ្មែរចេះតែកើនឡើងឥតឈប់ឈរ ដែលជាលេសឲ្យថៅកែចិន តម្លើងថ្លៃទំនិញជាប់ជាប្រចាំ ។

អ្វីដែលគួរកត់សំគាល់នៅក្នុងភូមិតូចដូចជាភូមិស្នាយពលនោះគឺ ភាពងាយស្រួលរបស់ជនជាតិចិន ក្នុងការបត់បែនសម្របសម្រួលធ្វើសមាហរណកម្មខ្លួនចូលមកក្នុងសង្គមខ្មែរ ។ ប្រសិនបើបុរសជនជាតិចិនខ្លះមិនទាន់អាចនិយាយភាសាខ្មែរបានច្បាស់ក៏ដោយ ក៏ប្រពន្ធ ឬ កូនចិនអាចនិយាយភាសាខ្មែរបានល្អឥតខ្ចោះដូចកូនចៅខ្មែរយើងដែរ ។ គ្រួសារជនជាតិចិននៅក្នុងភូមិ ច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ។ យាយចាស់ៗច្រើនទៅវត្ត និង ជួយផ្គត់ផ្គង់ធ្វើបុណ្យទានតាមប្រពៃណីខ្មែរ ថែមពីលើប្រពៃណីចិនរបស់ពួកគេផ្ទាល់ទៀតផង ។

ពួកចិនបានរៀបការកូនស្រីរបស់គេជាមួយកូនកម្លោះខ្មែរ ដែលភាគច្រើនធ្វើជាមន្ត្រីរាជការ ។ គួររំលឹកថា អាពាហ៍ពិពាហ៍ខ្មែរ-ចិននេះបាននាំឲ្យមានកូនកាត់ជាច្រើន ដែលបានទាមទារសញ្ជាតិកម្ពុជា តាំងពីទសវត្សរ៍ឆ្នាំ ១៩២០ (ដើម្បីបង់

ពន្ធតិច)[7]។ នៅសម័យនោះ អ្នកស្រែមិនសូវចូលចិត្តបញ្ជូនកូនទៅរៀននៅសាលាទេ ព្រោះចង់ទុកកូនឲ្យជួយធ្វើស្រែ ឬ ឃ្វាលគោក្របី ។ ក៏ប៉ុន្តែ ចំពោះអ្នកស្រែខ្លះដែលមានលទ្ធភាពបញ្ជូនកូនទៅសាលា ពួកគាត់បានទទួលរង្វាន់មកវិញ ដោយកូនដែលបានបញ្ចប់ការសិក្សា បានទទួលការងារធ្វើក្នុងរាជការ ហើយកូននោះក៏ជួយទំនុកបំរុងតបស្នងសងគុណឪពុកម្តាយវិញដែរ ។

នៅទសវត្សរ៍ឆ្នាំ ១៩៥០ អ្នកដែលរៀនចប់សាលាបឋមសិក្សា[8] អាចចូលធ្វើគ្រូបង្រៀនបាន ។ នៅទសវត្សរ៍ឆ្នាំ ១៩៦០ អ្នកដែលរៀន និង ប្រឡងជាប់សញ្ញាប័ត្រឌីប្លូម[9] ទើបអាចប្រឡងធ្វើជាគ្រូបង្រៀន ។ ក៏ប៉ុន្តែអ្នកដែលមានសញ្ញាប័ត្រកាន់តែខ្ពស់ ក៏អាចចូលបំរើរាជការក្នុងមុខតំណែងកាន់តែធំ ។ ប្រាក់ខែរបស់គ្រូបង្រៀនមានប្រហែល ១០០ ដុល្លារ ក្នុងមួយខែ ដែលជាប្រាក់ខែខ្ពស់បង្គួរសំរាប់ប្រជាពលរដ្ឋខ្មែរក្នុងសម័យនោះ បើប្រៀបធៀបទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋធម្មតា ។ មុខរបរគ្រូបង្រៀនមានប្រជាប្រិយភាពខ្លាំងណាស់ដែលធ្វើឲ្យពួកចិននៅក្នុងភូមិ ចង់លើកកូនក្រមុំឲ្យ ។ លោកគ្រូកម្លោះៗដែលចេញមកធ្វើការដំបូង ពួកចិន ចង់លើកកូនឲ្យដោយសន្យាទិញម៉ូតូថ្មីជាចំណងដៃថែមទៀតផង ។ តាមធម្មតា ការងារនៅក្នុងរាជការត្រូវបានគេគោរពរាប់អានណាស់ ។ គ្រូបង្រៀនត្រូវបានពង្រាយទៅតាមភូមិនានាជាច្រើនទូទាំងប្រទេស ដូចនេះទើបពួកលោកគ្រូ ៗ ទទួលនូវការពេញនិយមជាទូទៅ ។

---

7 Sorn Samnang, L'évolution de la société cambodgienne entre les deux guerres mondiales (1919-1939), Thèse d'Histoire, Université Paris 7, Octobre 1995, p. 174.

8 អ្នកមាន វិញ្ញាបនបត្របញ្ចប់បឋមសិក្សា ដែលខ្មែរយើងសម័យនោះហៅថាជាប់ សេកទីហ្វីកា Certificat ។

9 ពាក្យឌីប្លូមនេះប្រែពីភាសាបារាំង Diplôme d'Etudes Secondaires du Premier Cycle (D.E.S.P.C) ដែលខ្មែរយើងហៅថា សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬ សញ្ញាបត្របញ្ចប់ការសិក្សាថ្នាក់ទី៩ (Grade 9) ។